# Parenting Payment

Parenting Payment
គឺជាប្រាក់ផ្គត់ផ្គង់លើប្រាក់ចំណូលសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាលដើម្បីជួយលើថ្លៃចំណាយចិញ្ចឹមកូន។

## សិទ្ធិទទួលបាន Parenting Payment

Parenting Payment ត្រូវបានបើកឲ្យអ្នកមើលថែកូនជាចម្បង។ ឪពុក ឬម្តាយ ឬអាណាព្យាបាលតែម្នាក់ប៉ុណ្ណោះដែលអាច ទទួលបានប្រាក់នេះ។ លោកអ្នកអាចមានសិទ្ធិទទួលបាន Parenting Payment ក្នុងភាពជាឪពុកឬម្តាយ ជីដូនឬជីតា ឬអ្នកមើលថែកូនចិញ្ចឹម ប្រសិនបើ៖

- លោកអ្នកនៅលីវ ហើយមើលថែយ៉ាងហោចណាស់កូនម្នាក់ដែលមានអាយុតិចជាងប្រាំបីឆ្នាំ ឬ
- លោកអ្នកមានដៃគូកំណាន់ម្នាក់ ហើយមើលថែយ៉ាងហោចណាស់កូនម្នាក់ដែលមានអាយុតិចជាងប្រាំមួយឆ្នាំ ហើយ
- ប្រាក់ចំណូល និងទ្រព្យសម្បត្តិទាំងរបស់លោកអ្នក និងទាំងរបស់ដៃគូកំណាន់របស់លោកអ្នក (ប្រសិនបើលោកអ្នក មានដៃគូកំណាន់ម្នាក់) ស្ថិតនៅក្រោមចំនួនដ៏ជាក់លាក់, ហើយ
- លោកអ្នកបានបំពេញតាមតម្រូវការនៃការស្នាក់នៅក្នុងប្រទេស ហើយ
- លោកអ្នកអាចបំពេញតាមតម្រូវការនៃការចូលរួម ប្រសិនបើចាំបាច់។

## អត្រាប្រាក់ Parenting Payment

ចំនួននៃ Parenting Payment ដែលលោកអ្នកទទួលបាន គឺអាស្រ័យទៅលើស្ថានភាពគ្រួសាររបស់លោកអ្នក។ អត្រានៃប្រាក់នេះត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី២០ ខែមីនា និងថ្ងៃទី២០ ខែកញ្ញារៀងរាល់ឆ្នាំ។ ចំពោះអត្រាចុងបំផុត សូមបើកមើលវិប សាយ humanservices.gov.au/parentingpayment

# តេស្តលើប្រាក់ចំណូលនិងទ្រព្យសម្បត្តិសម្រាប់ Parenting Payment

ចំនួននៃ Parenting Payment ដែលលោកអ្នកទទួលបាន
គឺអាស្រ័យទៅលើប្រាក់ចំណូលនិងទ្រព្យសម្បត្តិទាំងរបស់លោក
អ្នក និងទាំងរបស់ដៃគូកំណាន់របស់លោកអ្នក (ប្រសិនបើលោកអ្នកមានដៃគូកំណាន់ម្នាក់)។

ទ្រព្យសម្បត្តិគឺជាអចលនទ្រព្យ ឬជាទ្រព្យណាមួយដែលលោកអ្នកមានកម្មសិទ្ធិមួយផ្នែក ឬទាំងអស់។ វារាប់បញ្ចូលទាំងទ្រព្យ
សម្បត្តិកាន់កាប់នៅក្រៅប្រទេសអូស្ត្រាលី និងបំណុលដែលគេជំពាក់លោកអ្នកផងដែរ។

តេស្តលើប្រាក់ចំណូលនិងទ្រព្យសម្បត្តិត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី២០ ខែមីនា ថ្ងៃទី១ ខែកក្កដា និងថ្ងៃទី២០ ខែកញ្ញារៀងរាល់ ឆ្នាំ។ ចំពោះអត្រាចុង
បំផុតសូមបើកមើលវ៉ិបសាយ [humanservices.gov.au/parentingpayment](humanservices.gov.au/parentingpayment)

# ព័ត៌មានបន្ថែម

ចំពោះព័ត៌មានបន្ថែមអំពី Parenting Payment:

- បើកមើលវ៉ិបសាយ [humanservices.gov.au/parentingpayment](humanservices.gov.au/parentingpayment)
- ទូរស័ព្ទលេខ **131 202** ដើម្បីនិយាយទៅកាន់នរណាម្នាក់ជាភាសា [Khmer/ខ្មែរ] ឬ
- អញ្ជើញទៅ service centre ណាមួយ។

# Parenting Payment

Parenting Payment is income support for parents or guardians to help with the cost of raising children.

## Eligibility for Parenting Payment

Parenting Payment is paid to the principal carer of a child. Only one parent or guardian can receive the payment. You may qualify for Parenting Payment as a parent, grandparent, or foster carer, if:

- you are single and care for at least one child aged less than eight, or
- you have a partner and care for at least one child aged less than six, and
- the income and assets of both you and your partner (if you have one) are below certain amounts, and
- you meet residence requirements, and
- you are able to meet participation requirements if needed.

## Payment rates for Parenting Payment

The amount of Parenting Payment you get depends on your family situation. The rates are updated on 20 March and 20 September each year. For the latest rates visit **humanservices.gov.au/parentingpayment**

## Income and assets tests for Parenting Payment

The amount of Parenting Payment you get depends on the income and assets of both you and your partner (if you have one).

An asset is any property or possession you own either partly or wholly. It includes assets held outside Australia and debts owing to you.

The income and assets tests are updated on 20 March, 1 July and 20 September each year. For the latest rates visit **humanservices.gov.au/parentingpayment**

## More information

For more information about Parenting Payment:

- visit **humanservices.gov.au/parentingpayment**
- call **131 202** to speak to someone in your language, or
- visit a service centre.